**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៧.០១៧.២០៥៨.ធ.ស.ក

ABA' BANK
លិខិតចូល Letter in
No : 163
Time: 2:45 PM
Date: 06. Dec. 17

ថ្ងៃអង្គារ ២រោច ខែមិគសិរ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែធ្នូ គ.ស. ២០១៧

**ជម្រាបមក**
**លោក លោកស្រី អគ្គនាយក អគ្គនាយិកា គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ**

**កម្មវត្ថុ** ៖ ការទប់ស្កាត់ការប្រើប្រាស់ ចរាចរ ទិញ លក់ ទូទាត់ និងផ្សព្វផ្សាយ រូបិយវត្ថុ Crypto (Crypto Currencies) និងឧបករណ៍អេឡិចត្រូនិកប្រហាក់ប្រហែលដែលមិនមានការទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជានៅក្នុងប្រព័ន្ធធនាគារ និងហិរញ្ញវត្ថុនៃប្រទេសកម្ពុជា។

**យោង** ៖ សេចក្តីប្រកាសព័ត៌មានរបស់ធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី០៧ ខែមេសា គ.ស.២០១៤។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប លោក លោកស្រី អគ្គនាយក អគ្គនាយិកាគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទាំងអស់ឲ្យបានជ្រាបថា ធនាគារជាតិនៃកម្ពុជាបានពិនិត្យឃើញថាបច្ចុប្បន្នមានការ ចរាចរ ទិញ លក់ ទូទាត់ ផ្សព្វផ្សាយ រូបិយវត្ថុ Crypto (Crypto Currencies) ដូចជា BitCoin និងឧបករណ៍អេឡិចត្រូនិកប្រហាក់ប្រហែល ដោយមិនមានច្បាប់អនុញ្ញាត និងមិនមានការទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា។ ការផ្សព្វផ្សាយ និងការធ្វើប្រតិបត្តិការទាំងនេះ អាចបង្កហានិភ័យដល់សាធារណជន និងជាមធ្យោបាយសម្រាប់ការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងទីផ្សារងងឹត ដោយសារអ្នកប្រើប្រាស់និងវិនិយោគិនមួយចំនួនមិនមានការយល់ដឹងពីរូបិយវត្ថុ Crypto (Crypto Currencies) ដែលងាយរងការឆបោកផ្សេងៗ។

ធនាគារជាតិនៃកម្ពុជា សូមហាមឃាត់ចំពោះគ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ក្នុងការធ្វើប្រតិបត្តិការពាក់ព័ន្ធនឹងការ ចរាចរ ទិញ លក់ ទូទាត់ ផ្សព្វផ្សាយ រូបិយវត្ថុ Crypto (Crypto Currencies) និងឧបករណ៍អេឡិចត្រូនិកប្រហាក់ប្រហែលដែលមិនមានការទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា ទោះក្នុងរូបភាពណាមួយក៏ដោយ។

ធនាគារជាតិនៃកម្ពុជា សង្ឃឹមយ៉ាងមុតមាំថា លោក លោកស្រី អគ្គនាយក អគ្គនាយិកា គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទាំងអស់ នឹងបន្តគាំទ្រនិងសហការអនុវត្តតាមសេចក្តីណែនាំនេះឲ្យមានប្រសិទ្ធភាពខ្ពស់។ ប្រសិនបើមានគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុណាមួយល្មើសនឹងសេចក្តីណែនាំនេះ នឹងទទួលរងទណ្ឌកម្មតាមច្បាប់ជាធរមាន។

សូម លោក លោកស្រី អគ្គនាយក អគ្គនាយិកា ទទួលនូវការរាប់អានពីខ្ញុំ ។

**ត.ម ទេសាភិបាល**
**អគ្គនាយកត្រួតពិនិត្យ**

**រ័ត្ន សុវណ្ណោរៈ**